# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីបុណ្យពិសាខបូជា

web site: hoksavann.org

ថ្ងៃទី១៤ ឧសភា ២០០៥

រៀងរាល់ឆ្នាំ ពុទ្ធសាសនិកជនពិភពលោក ជាពិសេសពុទ្ធសាសនិកជនខ្មែរតែងតែធ្វើពិធីបុណ្យមួយហៅថា «បុណ្យពិសាខបូជា» ។ បុណ្យនេះធ្វើឡើងដើម្បីរំលឹកនូវបុព្វហេតុ៣ប្រការដែលកើតឡើងក្នុងសម័យពុទ្ធកាល គឺ១- ព្រះពោធិសត្វព្រះនាមព្រះសិទ្ធត្ថប្រសូត, ២- ព្រះអង្គត្រាស់ជាព្រះពុទ្ធឃើញអរិយសច្ច៤ គឺសេចក្ដីទុក្ខ, ហេតុដែលនាំឲ្យកើតទុក្ខ ការរំលត់ទុក្ខ និងវិធីប្រតិបត្តិដើម្បីការរំលត់ទុក្ខ, ៣-ព្រះអង្គរំលត់ខន្ធបរិនិព្វាន ។ បុព្វហេតុទាំងបីនេះកើតឡើង នៅថ្ងៃទី១៥កើតខែពិសាខដូចគ្នា ។ បុណ្យនេះគេចាត់ទុក ជាបុណ្យសំខាន់ជាងគេក្នុងព្រះពុទ្ធសាសនា ។ ពាក្យថាពិសាខបូជា កាត់ជាពីរបទ គឺពិសាខមួយបទ និងបូជាមួយបទ ។ ពាក្យថាពិសាខ គឺជាឈ្មោះខែមួយក្នុងចន្ទគតិ គឺខែពិសាខ ឯពាក្យថាបូជា ប្រែថាការថ្វាយ ការប្រគេន ការជូន តាមពាក្យខ្ពស់ទាប បើនិយាយអំពីការថ្វាយឬប្រគេនវត្ថុផ្សេងៗ ។ បូជាម៉្យាងទៀត ប្រែថាការប្រតិបត្តិតាម ។ រួមពាក្យទាំងពីរបទ ពិសាខបូជាប្រែថាការបូជាក្នុងខែពិសាខ គឺជាបុណ្យរំលឹកដល់បុព្វហេតុបីប្រការក្នុងសម័យពុទ្ធកាល ក្នុងខែពិសាខដូចពោលមកហើយ ។

ព្រះពុទ្ធនាមដើម សិទ្ធត្ថ: គោត្តនាម គោតម ប្រសូតនៅសតវត្សទី៦ មុនគ.ស. ព្រះមាតាព្រះនាមសិរិមហាមាយា ព្រះបិតាព្រះនាមព្រះបាទសុទ្ធោទន ជាស្ដេចសោយរាជ្យនៅនគរកបិលពស្តុ ប្រទេសឥណ្ឌា ។ ព្រះជន្ម១៦ព្រះវស្សា ព្រះអង្គរៀបអភិសេកជាមួយព្រះនាងពិម្ពា មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមរាហុល ។ ព្រះជន្ម២៩ព្រះវស្សា ព្រះអង្គចេញទៅបួសជាតាបសឥសី ស្វែងរកការត្រាស់ដឹង ដើម្បីរំដោះទុក្ខមនុស្សសត្វ ។ ដំបូងព្រះអង្គបានសិក្សាពិសោធន៍ជាមួយនឹងគ្រូប្រដៅសាសនាដ៏ល្បីឈ្មោះនាសម័យនោះ គឺគ្រូឈ្មោះអាឡារតាបស និងឧទកតាបស តែពុំបានសំរេច ទើបលាអាចារ្យទាំងពីរនោះ រកវិធីប្រតិបត្តិដោយខ្លួនព្រះអង្គឯងវិញ ។ ព្រះអង្គធ្វើទុក្ករកិរិយា គឺការព្យាយាមធ្វើបាបកាយអស់៦ឆ្នាំ មានការបន្ថយចង្ហាន់ជាដើម តែវិធីនេះនៅតែពុំបានសំរេចទៀត ទើបសោយចង្ហាន់តាមធម្មតាវិញ ។ ទីបំផុតនៃការពិសោធន៍ ព្រះអង្គរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ប្រការ ហើយដោយការប្រតិបត្តិតាមមាគ៌ានោះ ទើបធ្វើឲ្យព្រះអង្គឃើញអរិយសច្ច៤ បានត្រាស់ជាព្រះពុទ្ធនៅក្រោមដើមពោធិព្រឹក្ស សព្វថ្ងៃកន្លែងនោះហៅថា ពោធគយានៃប្រទេសឥណ្ឌា ក្នុងព្រះជន្ម៣៥ព្រះវស្សា ។ បន្ទាប់មក ព្រះអង្គសំដែងធម្មទេសនាប្រោសសត្វអស់រយ:វេលា៤៥ឆ្នាំ ។ លុះព្រះជន្ម៨០វស្សា ព្រះអង្គរំលត់ខន្ធបរិនិព្វាន ទុកធម៌វិន័យដែលព្រះអង្គសំដែងសំរាប់មនុស្សសត្វប្រតិបត្តិរហូតមកដល់សព្វថ្ងៃនេះ ។

ក្នុងយប់ថ្ងៃបុណ្យពិសាខបូជា ពុទ្ធបរិស័ទខ្មែរបាននាំគ្នាទៅវត្តនមស្សការព្រះរតនត្រ័យសមាទានសីល ប្រកាសពិសាខបូជា វេរគ្រឿងសក្ការ: ស្ដាប់ព្រះសង្ឃចណរើនព្រះបរិត្តនិងទេសនា ។ លុះព្រឹកឡើងមានពិធីរាប់បាត្រនិងវេរចង្ហាន់ប្រគេនព្រះសង្ឃ ។ ក្នុងឱកាសបុណ្យពិសាខបូជានេះ រាជរដ្ឋាភិបាលខ្មែរបានអនុញ្ញាតឲ្យមន្ត្រីរដ្ឋការឈប់ធ្វើការ ដើម្បីបំពេញបុណ្យកុសលនេះ ដែលចាត់ទុកជាបុណ្យជាតិស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាដែលចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ជិតបរិនិព្វាន ព្រះអង្គបានត្រាស់ជាចុងក្រោយថា សង្ខារទាំងឡាយមានការអស់ទៅសូន្យទៅជាធម្មតា ចូរអ្នករាល់គ្នាខំប្រតិបត្តិដ៏សមគួរដល់ធម៌ ដោយសេចក្ដីមិនប្រមាទចុះ ។ នៅពេលនោះ ភិក្ខុទាំងឡាយដែលកំពុងគង់នៅជិតព្រះពុទ្ធបរមគ្រូ លុះបានជ្រាបថាព្រះអង្គនឹងបរិនិព្វានក៏សំដែងនូវការក្រៀមក្រំសោកស្ដាយចំពោះព្រះអង្គ ចំណែកព្រះអរហន្តជាព្រះខីរណាស្រព កើតក្ដីសង្វេគចំពោះសង្ខារ ចំពោះសព្វសត្វ ដោយគិតថា សូម្បីតែព្រះពុទ្ធជាបុគ្គលឈ្នះមារ ក៏ព្រះអង្គរលត់ខន្ធបរិនិព្វានដែរ ។ ប្លែកតែភិក្ខុមួយអង្គ គេចខ្លួនពីទីនេះទៅចំរើនធម៌តែម្នាក់ឯង ធ្វើឲ្យភិក្ខុទាំងឡាយលើកទោសថា ភិក្ខុអង្គនេះពុំគោរពព្រះពុទ្ធជាម្ចាស់ទេ ។ ដើម្បីកំចាត់បង់សេចក្ដីសង្ស័យ ព្រះពុទ្ធបានត្រាស់ឲ្យហៅភិក្ខុនោះមកសាកសួរ ភិក្ខុនោះឆ្លើយថា ខ្ញុំព្រះអង្គពុំទាន់បានសំរេចមគ្គផលអ្វីនឹងគេទេ ខ្ញុំព្រះអង្គគេចទៅចំរើនធម៌ឲ្យបានសំរេចមគ្គផលមុនព្រះអង្គនិព្វាន ។ ព្រះពុទ្ធបានប្រទានពរសព្វសាធុកាជាប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ បើជនណាមួយគោរពរាប់អានតថាគត ចូរធ្វើតាមភិក្ខុអង្គនេះ ដោយប្រតិបត្តិតាមសីលសមាធិបញ្ញា រហូតសំរេចមគ្គផលនិព្វាន ឈ្មោះថាបូជាតថាគតដោយបត្តិបត្តិបូជា ជាបូជាដ៏ឧត្តមប្រសើរជាងសក្ការបូជាដោយផ្កាទៀន ធូប ជាដើមទៅទៀត ។៚